**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ.៣ ០១៧.៧៥៨ ស.ណ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## យុទ្ធនាការស្រលាញ់ប្រាក់រៀល

អគ្គបេឡាធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា ដើម្បីរួមចំណែកអបអរសាទរពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីខ្មែរ អគ្គបេឡាធនាគារជាតិនៃកម្ពុជា នឹងរៀបចំយុទ្ធនាការស្រលាញ់ប្រាក់រៀល ចាប់ពីថ្ងៃទី១១ ដល់ ១៥ ខែកញ្ញា ឆ្នាំ២០១៧ ។

យុទ្ធនាការនេះ នឹងផ្តល់ឱកាសជូនសាធារណជន ដែលមានក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែក មកប្តូរយកក្រដាសប្រាក់ថ្មីពីបញ្ជរបេឡាធនាគារជាតិនៃកម្ពុជា ។ ការប្តូរក្រដាសប្រាក់នេះនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១ ដល់ ១៥ ខែកញ្ញា ឆ្នាំ២០១៧ រៀងរាល់ម៉ោងធ្វើការ នៅគ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្តាល) ។

ក្នុងឱកាសនៃពិធីបុណ្យភ្ជុំបិណ្ឌនេះ អគ្គបេឡាធនាគារជាតិនៃកម្ពុជា សូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រីទាំងអស់ សូមជួបប្រទះតែពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**អគ្គបេឡា**

**ថា យ៉ាវ**


ទូរស័ព្ទទំនាក់ទំនង៖ (៨៥៥-៨៩) ៩៨៨ ៨៨១
(៨៥៥-៩៧) ៩៥៧ ២២២២
អ៊ីម៉ែលទំនាក់ទំនង៖ issue.dept@nbc.org.kh